D00015

(15)

TS

បទសំភាសន៍ជាមួយសមមិត្តនារី ទុយ គិន

"អតីតកម្មាភិបាលនៃបន ប៉ុល ពត ធ្វើការនៅមន្ទីរ ស ២១"

"បច្ចុប្បន្នជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែង"

នាងខ្ញុំឈ្មោះ ទុយ គិន ភេទស្រី អាយុ ៣៥ ឆ្នាំ ភូមិកំណើតនៅភូមិលេខ ៥ ឃុំពោធិព្រាន ស្រុកកោះធំ ខេត្តកណ្ដាល ។ ខ្ញុំជាសមាជិករបស់គេទេ គេបានបញ្ជាអោយខ្ញុំសំលាប់គេ ខ្ញុំក៏ធ្វើតាមគេទៅ ខ្ញុំបានសំលាប់ចំនួន ៣០០ នាក់ ។ ខ្ញុំចូលបំរើបដិវត្តនៅក្នុងឆ្នាំ ១៩៧៣ ហើយចូលធ្វើការនៅទួលស្លែងឆ្នាំ ១៩៧៨ ខ្ញុំនៅទីនោះបាន ១ ខែហើយចប់ភារកិច្ច ។ នៅក្នុងគុកទួលស្លែងគេអត់អោយខ្ញុំដើរផ្ដេសផ្ដាសទេគឺនៅមួយកន្លែង ។ ទីកន្លែងសំលាប់ខ្ញុំមិនបាននឹកឃើញទេ ប៉ុន្តែប្រហែលជានៅជុំវិញទួលស្លែង ពេលយកអ្នកទោសទៅសំលាប់គឺទៅតែម្នាក់ឯងទេ ពេលដែលសំលាប់គេ ខ្ញុំមានមនោសញ្ចេតនាអាណិតគេតែធ្វើម៉េចបើគេបញ្ជាអោយខ្ញុំធ្វើ អ្នកទោសគឺសំលាប់ដោយឆក់ខ្សែភ្លើង ។ ខ្ញុំគ្រាន់តែជាអ្នករៀបចំប្រដាប់ប្រដាអោយគា តែពួកវា ២ នាក់ទៀតជាអ្នកធ្វើដោយផ្ទាល់ដៃ ខ្ញុំគ្រាន់តែទៅហៅអ្នកទោសយកមកអោយគេ គ្នាគេគឺមានប្រុសៗ ២ នាក់ដែលធ្វើផ្ទាល់ដៃ ដូច្នេះខ្ញុំគ្រាន់តែជាអ្នកទៅបញ្ជាញអ្នកទោសមកអោយគេ ហើយប្រុស ២ នាក់វាធ្វើដោយផ្ទាល់ដៃ ។ ក្នុងការឆក់ខ្សែភ្លើងនេះ គឺឆក់រហូតដល់ស្លាប់តែម្ដង បន្ទប់ឆក់ខ្សែភ្លើងគឺនៅខាងក្រៅបរិវេណទួលស្លែង ផ្ទះដែលខ្ញុំស្នាក់នៅគឺនៅផ្សារបឹងកេងកង ។ កាលខ្ញុំធ្វើការនៅគុកទួលស្លែងមានអាយុ ២៥ ឆ្នាំ ។

ពេលបញ្ជាញអ្នកទោសម្ដង ខ្ញុំបានទទួលលិខិតមួយច្បាប់ពី ឌុច ខ្ញុំមិនបានទៅជួបប្រធាន ឌុច ផ្ទាល់ទេ លិខិតនោះបានសរសេរថា : សូមអញ្ជើញសមមិត្តនារី... អោយបញ្ជាញទោសឈ្មោះ... ក្នុងពេលទៅយកអ្នកទោសម្ដងតែ ១ នាក់ទេមកឆក់ខ្សែភ្លើង ។ ខ្ញុំទៅយកអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងរួមគឺនៅជាន់ទី ៣ ។ នៅក្នុងទួលស្លែងខ្ញុំស្គាល់តែអាហ៊ុយ និងប្រធានធំជាងគេគឺ ឌុច ។ ប្រធាន ឌុច មានលក្ខណៈកាចណាស់ ជេរស្ដីគេ បើគេមិនអនុវត្តតាមគាត់ៗ ចាប់អ្នកដែលប្រឆាំង និង បញ្ជារបស់គាត់ដែរ ឧទាហរណ៍ ដូចជាបង ភាព ធ្វើការនៅខាងទទួលធ្វើបាយត្រូវពួកអា ឌុច សំលាប់ចោលព្រោះមិនគោរពវិន័យរបស់វា បងភាពបានលួចយកបាយទៅអោយអ្នកទោសហូប ។ ខ្ញុំមិនបានជួបអ្នកធ្វើការនៅទួលស្លែងជំនាន់ ប៉ុល ពត ទេ ពេលខ្ញុំត្រឡប់មកវិញមិនដឹងថាគេមកប្ដឹងអត់ ។ ខ្ញុំមានឪពុកម្ដាយនៅរស់ទាំងអស់ ហើយមានបងប្អូន ៤ នាក់ប្រុស ១ ស្រី ៣ ។ សព្វថ្ងៃខ្ញុំនៅជាមួយឪពុកម្ដាយខ្ញុំ បងប្រុសខ្ញុំធ្វើជាប្រធានក្រុមនៅក្នុងភូមិនេះ ។

មន្ទីរ ស.២១

# ប្រវត្តិរូបសង្ខេប

407

K00077



គាង - គិន

| | | | |
|---|---|---|---|
| ឈ្មោះដើម | នាង . គិន | ឈ្មោះប្រែ | នាង . គិន |
| អាយុ ២៥ ឆ្នាំ | នាទីពីមុន ប្រ.ក្រុម | នាទីបច្ចុប្បន្ន | យុ.នារី ភេទស្រី |
| របររកស៊ីមុនប.វ | ស្រែ.ចំការ | វណ្ណៈភាព | ក.កណ្ដាលក្រោម |
| ថ្ងៃចូលប.វ | ៥.២.៧៣ | អ្នកនាំចូល | យ៉ុន |
| ថ្ងៃចូលស.ព | | អ្នកទទួលនាម | |
| ថ្ងៃចូលបក្ស | | អ្នកឧទ្ទេសនាម | |
| រយៈពេលត្រៀម | ថ្ងៃពេញសិទ្ធិ | អ្នកបំពេញ | |
| កម្រិតវប្បធម៌ | រៀនថ្នាក់ទី មើលរួច | | |

## អំពីស្រុកកំណើត

| | | | |
|---|---|---|---|
| ទីលំនៅនៅភូមិ | ភូមិថ្មី | ឃុំ | ពោធិបាន |
| ស្រុក | ១៨ | តំបន់ ឬ ខេត្ត | ២៥ |
| អតីតៈកងចាស់ | ៧០៣ | បច្ចុប្បន្នមកកង | ១៧ |

ពាក់ពាន់ផ្ទាល់ខ្លួន រត់ទៅផ្ទះម្ដង ។

## អំពីបញ្ហាគ្រួសារ

| | | | |
|---|---|---|---|
| ប្ដី ឈ្មោះ | | ឈ្មោះប្រែ | |
| ក្រសួងប្ដី | | នាទីប្ដី | |
| របររកស៊ីមុនប.វ | | កម្រិតវប្បធម៌ | |
| មានកូនប្រុសចំនួន | នាក់ | មានកូនស្រីចំនួន | នាក់ |
| ឪពុកឈ្មោះដើម | នាង . ទុយ | ឈ្មោះប្រែ | |
| ក្រសួងឪពុកនៅ | សហករណ៍ | នាទីឪពុក | |
| ម្ដាយឈ្មោះដើម | ញ៉ាំវ . សយ | ឈ្មោះប្រែ | |
| ក្រសួងម្ដាយនៅ | សហករណ៍ | នាទីម្ដាយ | |
| ថ្ងៃចូលអ.ភ:២៣.១២.៧៥ ថ្ងៃឯក: | | ថ្ងៃរត់: | ថ្ងៃពលី |

សេចក្ដីផ្សេងៗ :